**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ០០២ មស.រាប

# របាយការណ៍
# បូកសរុបការងារប្រចាំឆ្នាំ២០១៥និងទិសដៅឆ្នាំ២០១៦
# របស់ក្រសួងមុខងារសាធារណៈ

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៥ នៃរដ្ឋសភា បានបង្កើតក្រសួងមុខងារសាធារណៈ និង ប្រគល់ភារកិច្ចឱ្យបំពេញមុខងារនិងបេសកកម្មសំខាន់ គឺ "ដឹកនាំនិងគ្រប់គ្រងវិស័យមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា" និង "ដឹកនាំការងារកែទម្រង់រដ្ឋបាលសាធារណៈ។

ក្នុងរយៈពេលមួយឆ្នាំ នៃការអនុវត្តន៍មុខងារនិងបេសកកម្មរបស់ខ្លួន ក្រសួងមុខងារសាធារណៈបានប្រកាន់ខ្ជាប់នូវភាពជាម្ចាស់និងភាពដឹកនាំឈរលើអភិក្រមបុរេសកម្មចំពោះការងារកែទម្រង់រដ្ឋបាលសាធារណៈ។ ក្រសួងបានសហការយ៉ាងល្អជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមជាមួយបណ្ដាដៃគូអភិវឌ្ឍន៍។ ថ្នាក់ដឹកនាំនិងមន្ត្រីរាជការរបស់ក្រសួង បានប្រមូលផ្ដុំរួមគ្នានូវសមត្ថភាព បញ្ញាញាណ ធនធានសម្ភារៈ និងថវិកា ក្នុងការដឹកនាំនិងអនុវត្តការងារកែទម្រង់ដោយសម្រេចបានសមិទ្ធផលយ៉ាងច្រើនជាប្រយោជន៍ដល់មន្ត្រីរាជការ ការរៀបចំនិងពង្រឹងស្ថាប័ន ព្រមទាំងការកែលម្អសេវាសាធារណៈឱ្យកាន់តែល្អប្រសើរឡើង។ សមិទ្ធផលសំខាន់ៗដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០១៥នេះ មានដូចខាងក្រោម៖

## I.<u>**សកម្មភាពថ្នាក់ដឹកនាំ**</u>

ថ្នាក់ដឹកនាំក្រសួងបានអញ្ជើញចូលរួមក្នុងអង្គប្រជុំ ការងារសង្គម និងកម្មវិធីនានា រួមមាន៖ (១) អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ចូលរួមនិងដឹកនាំអង្គប្រជុំអន្តរក្រសួង អង្គប្រជុំកម្រិតបច្ចេកទេស កិច្ចប្រជុំរបស់ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាម បែបប្រជាធិបតេយ្យនៅ ថ្នាក់ក្រោមជាតិ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ គណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ រដ្ឋបាលខេត្តឃុំ គណៈកម្មាធិការបើកផ្ដល់បៀវត្សតាមប្រព័ន្ធធនាគារ ដឹកនាំកិច្ចប្រជុំជាមួយដៃគូអភិវឌ្ឍន៍ "TWG" កិច្ចប្រជុំបូកសរុបសកម្មភាពក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងបានចុះរៀបចំវេទិកាសាធារណៈ ទៅតាមគោលដៅរៀងៗខ្លួន។ (២) កិច្ចប្រជុំពាក់ព័ន្ធនឹងសន្និសីទអាស៊ានស្ដីពីកិច្ចសហប្រតិបត្តិការអាស៊ានក្នុងវិស័យមុខងារសាធារណៈ កិច្ចប្រជុំ Cambodian-German Governmental Negotiation (៣)សវនការការងារជាមួយគណៈកម្មការទី៤ "មហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា" (៤)ធ្វើសន្និសីទការសែតចំនួន០២លើកស្ដីពីវឌ្ឍនភាពការងារ និងសមិទ្ធផលនានារបស់ក្រសួង និង ការអនុវត្តន៍កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ "NPAR" (៥) បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៤និងលើកទិសដៅការងារប្រចាំឆ្នាំ២០១៥ (៦)សិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីការងារកំណែទម្រង់ប្រព័ន្ធបៀវត្ស (៧)ជួបពិភាក្សាការងារជាមួយអង្គការអន្តរជាតិរួមមាន ៖ ADB, IMF, GIZ, Global Fund, JETRO, JICA, KOICA, UNDP និង World Bank (៨)ពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សាជូនមន្ត្រីរាជការក្រោមគម្រោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់កម្មវិធីអភិវឌ្ឍន៍ជនបទ អនុកម្មវិធីទី២

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

របស់ ADB (៩)ពិធីប្រគល់សញ្ញាបត្រកិត្តិបណ្ឌិតជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅរាជបណ្ឌិតសភាកម្ពុជា (១០) អញ្ជើញចូលរួមកម្មវិធីនានាតាមការអញ្ជើញរបស់គណៈកម្មការរៀបចំបុណ្យជាតិនិងអន្តរជាតិ និង ក្រសួង ស្ថាប័ន នានា និង (១១)បានអញ្ជើញទៅធ្វើទស្សនកិច្ចសិក្សានៅប្រទេសឥណ្ឌូនេស៊ី ជប៉ុន កូរ៉េ និង ស៊ុយអែត (១២)ថ្នាក់ដឹកនាំក្រុមការងាររបស់ក្រសួងមុខងារសាធារណៈបានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីចុះត្រួតពិនិត្យគ្រូបង្រៀននិងមន្ត្រីរដ្ឋបាល គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនជាប់កិច្ចសន្យានៅសាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យទូទាំង២៥រាជធានី ខេត្ត។

## II.ការអនុវត្តមុខងារនិងបេសកកម្មរបស់ក្រសួង

### ១.អង្គភាពថ្នាក់ជាតិ

#### ១.១.ការងារគ្រប់គ្រងបុគ្គលិក

**ក.ការគ្រប់គ្រងស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

- បានធ្វើការកែសម្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការនៃក្រសួងចំនួន៣៣៨ករណី។
- គិតត្រឹមខែធ្នូឆ្នាំ២០១៥ ក្រសួងមានមន្ត្រីរាជការសរុបចំនួន៦២៧នាក់/ស្ត្រី១៦៩នាក់ (ថ្នាក់កណ្តាលសរុបចំនួន៤១៩នាក់/ស្ត្រី១១៨នាក់ និង ថ្នាក់ក្រោមជាតិចំនួន២០៨នាក់/ស្ត្រី៥១នាក់)
- ស្ថិតិមន្ត្រីនៃក្រសួងមុខងារសាធារណៈ៖ (១)រដ្ឋមន្ត្រីនិងឋានៈស្មើរដ្ឋមន្ត្រីចំនួន០៣នាក់ (២)រដ្ឋលេខាធិការនិងឋានៈស្មើរដ្ឋលេខាធិការចំនួន០៥នាក់/ស្ត្រី០១នាក់ (៣)អនុរដ្ឋលេខាធិការនិងឋានៈស្មើអនុរដ្ឋលេខាធិការចំនួន១៣នាក់/ស្ត្រី០៣នាក់ (៤)អគ្គនាយកនិងឋានៈស្មើអគ្គនាយកចំនួន០៥នាក់ (៥)អគ្គនាយករងចំនួន១៣នាក់/ស្ត្រី០៤នាក់ (៦)អគ្គាធិការចំនួន០១នាក់ (៧)អគ្គាធិការរងចំនួន០២នាក់ (៨)អធិការចំនួន០៧នាក់ (៩)ប្រធាននាយកដ្ឋាននិងឋានៈស្មើប្រធាននាយកដ្ឋានចំនួន១៩នាក់/ស្ត្រី០៣នាក់ (១០) ប្រធានអង្គភាពលទ្ធកម្មចំនួន០១នាក់ (១១)អនុប្រធាននាយកដ្ឋាននិងឋានៈស្មើអនុប្រធាននាយកដ្ឋានចំនួន៨៣នាក់/ស្ត្រី១៨នាក់ (១២)ប្រធានការិយាល័យចំនួន៥៥នាក់/ស្ត្រី២០នាក់ (១៣)អនុប្រធានការិយាល័យចំនួន៥១នាក់/ស្ត្រី២០នាក់ (១៤)មន្ត្រីចំនួន១៦២នាក់/ស្ត្រី៤៨នាក់។

**ខ.ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិល**

- បានបញ្ជូនមន្ត្រីរាជការស៊ីវិលរបស់ក្រសួងទៅចូលរួមវគ្គបណ្តុះបណ្តាល ដូចខាងក្រោម៖

| បរិយាយ | ក្នុងប្រទេស | ក្រៅប្រទេស |
|---|---|---|
| ចំនួន | ១៦១៦នាក់ (ស្ត្រី២០០នាក់) | ៥៣នាក់ (ស្ត្រី១៧នាក់) រួមមានប្រទេសប្រ៊ុយណេដារ៉ូសាឡាម ចិន ឥណ្ឌា ឥណ្ឌូនេស៊ី កូរ៉េ ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបុរី ស្រីលង្កា ថៃ និង វៀតណាម |

#### ១.២.ការងារនីតិកម្មនិងវិវាទមុខងារសាធារណៈ

- បានចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ និង លិខិតបទដ្ឋានគតិយុត្តចំនួន ១១៤លើក
- បានរៀបចំ (១)អនុក្រឹត្យលេខ១៤-១៥-២០-២១-៣៦-៣៧-៣៨-៤១-៦៥-១១៤-១៩១ និង (២)សារាចរលេខ ០១-០២-០៥ (៣)សេចក្តីណែនាំលេខ៤៩៧ និង ៤៩៨និង (៤)សេចក្តីជូនដំណឹងលេខ៣៦១
- បាននិងកំពុងរៀបចំសេចក្តីព្រាង (១)ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ (២)អនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា និង (៣)អនុក្រឹត្យស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត
- បានធ្វើលិខិតផ្តល់យោបល់លើ (១)ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានរបស់ក្រសួងបរិស្ថាន និង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (២)ការបង្កើតការិយាល័យស្រុកប្រតិបត្តិព្រែកភ្នៅ មណ្ឌលសុខភាពពោធិ៍មង្គលនៅខណ្ឌពោធិ៍សែនជ័យរបស់ក្រសួងសុខាភិបាល (៣)សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានផ្សព្វផ្សាយអនុក្រឹត្យលេខ ១១៤ អនក្រ.បក ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និង សារាចរលេខ ០៥ សរ ស្តីពីការ

កែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ជូនថ្នាក់ដឹកនាំនិងមន្ត្រីរាជការចំនួន០៧ខេត្ត រួមមានខេត្តកោះកុង បន្ទាយមានជ័យ ពោធិ៍សាត់ សៀមរាប មណ្ឌលគិរី កំពង់ធំ និងឧត្តរមានជ័យ

- បានចងក្រងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលជូនរដ្ឋសភា ក្រសួងបរិស្ថាន និងអង្គការ JICA។

១.៣.ការងារគ្រប់គ្រងក្របខណ្ឌ

- បានផ្តល់ទិដ្ឋាការលើសំណើសុំ៖
  + ទទួលស្គាល់លទ្ធផលប្រឡងក្របខណ្ឌថ្មីរបស់ក្រសួង ស្ថាប័នចំនួន៩៤២កន្លែង
  + ទទួលស្គាល់ក្របខណ្ឌពិសេសរបស់ក្រសួង ស្ថាប័នចំនួន១៩កន្លែង
  + ទទួលស្គាល់លទ្ធផលប្រឡងប្តូរក្របខណ្ឌរបស់ក្រសួង ស្ថាប័នចំនួន៤០៧កន្លែង
  + បានផ្តល់ក្របខណ្ឌបន្ថែមលើផែនការក្របខណ្ឌប្រចាំឆ្នាំ២០១៥ ចំនួន២០០កន្លែង ជូនរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលចំនួន០៤កន្លែង អង្គភាពប្រឆាំងអំពើពុករលួយចំនួន៥២កន្លែង ក្រសួងផែនការចំនួន ១១២កន្លែង ទីស្តីការគណៈរដ្ឋមន្ត្រីចំនួន៣២កន្លែង
  + ប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាចំនួន៦២៦៣នាក់ និង បុគ្គលិកអណ្តែតចំនួន៦៤៨១នាក់
- បានចាត់បញ្ជូនមន្ត្រី៣៩នាក់ ដើម្បីចូលរួមក្នុងគណៈកម្មការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលក្នុងក្របខណ្ឌ ក្រសួង ស្ថាប័នចំនួន១៧
- បានរៀបចំដំណើរការប្រឡងជ្រើសរើសក្របខណ្ឌថ្មីរបស់ក្រសួង ស្ថាប័នចំនួន០៧ (ក្រសួងមុខងារសាធារណៈ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ ក្រសួងធម្មការ និងសាសនា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល)
- បានធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងលក់និងទទួលពាក្យ ស្តីពីការប្រឡងជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងស្ម័គ្រចិត្តឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងធម្មការនិងសាសនាចំនួន២៨៨កន្លែង
- បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីផែនការប្រើប្រាស់ក្របខណ្ឌ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតសម្រាប់ឆ្នាំ២០១៦ របស់ក្រសួង ស្ថាប័ន។

១.៤.ការងារត្រួតពិនិត្យរដ្ឋបាលនិងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល

- បានធ្វើសំណើសុំសេចក្តីសម្រេចពីសម្តេចនាយករដ្ឋមន្ត្រីនិងផ្តល់ទិដ្ឋាការជូនក្រសួង ស្ថាប័នដូចខាងក្រោម៖

| ល.រ | ការបរិយាយ | សំណើសុំការសម្រេច | | បានផ្តល់ទិដ្ឋាការ | |
|---|---|---|---|---|---|
| | | សរុប | ស្ត្រី | សរុប | ស្ត្រី |
| ១ | ការផ្ទេរក្របខណ្ឌ | ១២ | ០១ | ៣៩២ | ៥៣ |
| ២ | ការតែងតាំង | ១៥២ | ២៣ | ១៥៣៣ | ៣៣៥ |
| ៣ | ការតាំងស៊ប់ក្នុងក្របខណ្ឌ | ១៦៩០ | ៤៦២ | ៤៧៣៤ | ២០៩៣ |
| ៤ | ការសុំធ្វើសមាហរណកម្មមន្ត្រីរាជការ | ១០២ | ៣៥ | | |
| ៥ | ការសុំប្តូរប្រភេទក្របខណ្ឌ | ១៦៤២ | ២៦២ | ៥១១ | ១៤៨ |
| ៦ | ការសុំដាក់ឱ្យចូលនិវត្តន៍ | ២២៩ | ៥៩ | ១៣៣ | ២០ |
| ៧ | ការសុំលុបឈ្មោះ | ០៣ | | | |
| ៨ | ការសុំស្ថិតភាពទំនេរគ្មានបៀវត្ស | ០១ | | ០២ | ០១ |
| ៩ | ការសុំនិយ័តកម្មឋានន្តរស័ក្តិនិងដំឡើងឋានន្តរស័ក្តិ | | | ២២ | ០៨ |
| ១០ | ការសុំដំឡើងកម្រិតប្រាក់បំណាច់មុខងារ | | | ៥៤២ | ១១៣ |
| ១១ | ការសុំរៀបបៀវត្ស | | | ៣៥ | |
| ១២ | ការសុំដាក់ឱ្យនៅក្រៅក្របខណ្ឌដើម | | | ០១ | |
| | សរុប | ៣៨៣១ | ៨៤២ | ៧៩០៥ | ២៧៧១ |

- បានពិនិត្យនិងផ្តល់យោបល់លើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល លើសំណុំបៀវត្សចំនួន៣៩៦សំណុំលិខិតនិងសលាកប័ត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិលចំនួន៧០២៨នាក់ (ស្ត្រី៣៥២៩នាក់)។

១.៥.ការងារគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានិងឯកសារមន្ត្រីរាជការស៊ីវិល

- បានរកឃើញបៀវត្សមិនប្រក្រតីដែលត្រូវបង្វែរចូលថវិការដ្ឋវិញចំនួន ៥,១៧១,០៣៧,៣៨០រៀល
- បានឆ្លើយតបនិងទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធតាមរយៈប្រព័ន្ធទូរស័ព្ទ Hot Line ចំនួន៤១៣ករណី
- បានកែប្រព័ន្ធគ្រប់គ្រងតារាងទូទាត់បៀវត្សឱ្យស្របតាម (១)អនុក្រឹត្យស្តីពីការសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល (២)សារាចរស្តីពីការបើកផ្តល់បៀវត្សសម្រាប់ខែមេសាឆ្នាំ២០១៥ និង (៣)កំពុងរៀបចំកែតម្រូវប្រព័ន្ធបោះពុម្ពសលាកប័ត្រចូលនិវត្តន៍ឱ្យស្របតាមសារាចរស្តីពីការកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ និង (៤)កំពុងរៀបចំប្រព័ន្ធរដ្ឋបាលអេឡិចត្រូនិច
- បានកែសម្រួលប្រព័ន្ធទិន្នន័យសម្រាប់ស្រង់ទិន្នន័យមន្ត្រីរាជការជាគ្រូបង្រៀន និងផ្នែករដ្ឋបាល និង គ្រូជាប់កិច្ចសន្យា និង ប្រព័ន្ធបញ្ជូននិងទទួលទិន្នន័យ (Drag&Drop System) លើផ្នែកការគ្រប់គ្រងអ្នកប្រើប្រាស់ និងធ្វើការសាកល្បងកម្មវិធីពេញលេញតាមមន្ទីរនានាក្នុងខេត្តកំពង់ស្ពឺ និង ក្រសួងមុខងារសាធារណៈ
- បានបញ្ចូលទិន្នន័យមន្ត្រីរាជការស៊ីវិលក្នុងប្រព័ន្ធបណ្ណសារចំនួន៥៩៣៦នាក់ និងបញ្ចូលចលនាប្រែប្រួលស្តីពីទីតាំងសលាកប័ត្ររបស់មន្ត្រីរាជការស៊ីវិលចំនួន១៥៩៦៤នាក់/១៦៩២៥នាក់ ដែលមានក្នុងកម្មវិធីគ្រប់គ្រងឯកសារឯកត្តជនមន្ត្រីរាជការស៊ីវិលនិងបានរៀបចំសលាកបត្រឡើងធ្នើរចំនួន៦០០៧សំណុំលិខិត
- បាន (១)ផ្ទៀងផ្ទាត់មន្ត្រីរាជការចូលនិវត្តន៍ជាមួយសលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិលចំនួន៤៤១នាក់ (២)បោះពុម្ពសលាកប័ត្រចូលនិវត្តន៍មន្ត្រីរាជការតាមក្រសួង ស្ថាប័ននានាចំនួន៣១២នាក់ (៣)កែតម្រូវអតីតភាពការងារមន្ត្រីរាជការស៊ីវិលនៅក្រសួងឧស្សាហកម្មនិងសិប្បកម្មចំនួន០២នាក់ (៤)បញ្ជាក់សលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិលជាផ្លូវការជូនមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈចំនួន០៣នាក់ (៥)ធ្វើសេចក្តីជូនដំណឹងមន្ត្រីចូលនិវត្តន៍ចំនួន៣០នាក់
- បានបញ្ចូលទិន្នន័យការចុះត្រួតពិនិត្យលើការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការ ជាគ្រូបង្រៀននិងផ្នែករដ្ឋបាល គ្រូបង្រៀនជាប់កិច្ចសន្យាចំនួន០៦រាជធានី ខេត្ត
- បានធ្វើការកែតម្រូវការប្រែប្រួលស្ថានភាពរបស់មន្ត្រីរាជការ (ឯកតា=នាក់) ដូចខាងក្រោម៖

| ល.រ | បរិយាយ | ថ្នាក់កណ្តាល | ថ្នាក់រាជធានី-ខេត្ត |
|---|---|---|---|
| ១ | មន្ត្រីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៧៣៧ | ១៥១៩ |
| ២ | មន្ត្រីចូលបម្រើការងារវិញក្រោយពីស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៤០៧ | ៨៣០ |
| ៣ | មន្ត្រីក្របខណ្ឌថ្មី | ១២៥៦ | ៣៤៩៩ |
| ៤ | មន្ត្រីតាំងស៊ប់ | ៤០១ | ២៥០៦ |
| ៥ | មន្ត្រីឡើងឋានៈ | ៣១៦៣ | ២៥៨៦ |
| ៦ | មន្ត្រីដល់អាយុចូលនិវត្តន៍ | ៤៨៦ | ៦៤៦ |
| ៧ | មន្ត្រីលុបឈ្មោះចេញពីតារាងទូទាត់បៀវត្ស | ៣៧៦ | ៨៩៣ |
| ៨ | មន្ត្រីប្តូរឋានន្តរស័ក្តិ | ៣៥ | ២៣៩ |
| ៩ | មន្ត្រីប្តូរក្របខណ្ឌ | ៧៨៦ | ១៥១១ |
| ១០ | មន្ត្រីឡើងថ្នាក់ប្រចាំឆ្នាំ | ១១៣០ | ៣២៥៩ |
| ១១ | មន្ត្រីទីប្រឹក្សា | ៣៥៥ | |
| ១២ | មន្ត្រីស្លាប់ | ០២ | ២២ |
| ១៣ | មន្ត្រីផ្ទេរចេញ | ៤៣១ | ១៥៧០ |
| ១៤ | មន្ត្រីផ្ទេរចូល | ៦០៩ | ១៤៨២ |
| ១៥ | បញ្ចូលកូន | ១៤១២ | ៧៧៣៧ |

| ល.រ | បរិយាយ | ថ្នាក់កណ្តាល | ថ្នាក់រាជធានី-ខេត្ត |
|---|---|---|---|
| ១៦ | បញ្ចូលប្រពន្ធ | ៥៣២ | ១៣៤០ |
| ១៧ | មន្ត្រីនៅក្របខណ្ឌដើម | ១១ | ១៨ |
| ១៨ | មន្ត្រីសុំប្រាក់តំបន់ | | ១៨១៧ |
| ១៩ | មន្ត្រីលាឈប់ពីការងារ | ១១ | ៩៥ |
| ២០ | មន្ត្រីបេសកកម្មក្រៅប្រទេស | ២២ | |
| ២១ | មន្ត្រីសុំប្រាក់បំណាច់មុខងារ | ៥៧ | ៣១៥១ |
| ២២ | មន្ត្រីសុំដកប្រាក់មុខងារ | ៣៣ | ១៧ |
| ២៣ | មន្ត្រីពីរវេននិងថ្នាក់គួប | | ១៨៣៧២ |
| ២៤ | មន្ត្រីឡើងកម្រិតមុខងារ | ៥៦១ | ១៧២ |
| | សរុប | ១២៨១៣ | ៥៣១០៩ |

១.៦.ការងារមជ្ឈមណ្ឌលធនធានអាស៊ានកម្ពុជានិងកិច្ចសហប្រតិបត្តិការអន្តរជាតិ

- បានផ្តល់យោបល់លើសេចក្តីព្រាងផែនការសកម្មភាពឆ្នាំ២០១៦-២០២០ នៃអាស៊ាន-ចិនអាស៊ានកូរ៉េ និងអាស៊ាន-អាមេរិករបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានផ្តល់យោបល់លើ (១)ឯកសារដែលជាអនុសាសន៍របស់ក្រុមការងារជាន់ខ្ពស់ស្តីពីការពង្រឹងលេខាធិការដ្ឋានអាស៊ាន និងកិច្ចការត្រួតពិនិត្យអង្គភាពអាស៊ានឡើងវិញ (២)សេចក្តីព្រាងស្តីពីការសម្របសម្រួលតែមួយរបស់អាស៊ានសម្រាប់ដៃគូសន្ទនា និង ការអនុវត្តន៍លិខិតតូបករណ៍អាស៊ាន (Status of Ratification and Implementation of ASEAN Legal Instruments) ជូនក្រសួងអប់រំ យុវជន និងកីឡា (៣)ឯកសារស្តីពី "Action Lines in the APSC Blueprint Involving ASCC Sectoral" ជូនលេខាធិការដ្ឋានអាស៊ាន (៤)សេចក្តីព្រាងចុងក្រោយលើរបាយការណ៍លទ្ធផលនៃ ASCC Scorecard
- បានធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំប្រមុខមុខងារសាធារណៈអាស៊ាននិងអាស៊ានបូក៣ លើកទី២ នៅទីក្រុង Yangon ប្រទេសមីយ៉ាន់ម៉ាផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធ
- បានរៀបចំសំណុំបែបបទជូនថ្នាក់ដឹកនាំ ដើម្បីចូលរួមប្រជុំស្តីពី "The First ASEAN-OECD Centre of Government Meeting" និង "The First ASEAN-OECD Good Regulatory Practices Conference" និងកំពុងរៀបចំឯកសារជូនថ្នាក់ដឹកនាំចូលរួមកិច្ចប្រជុំស្តីពី "Public Sector and Policy Reform for National Development in Southeast Asia" នៅប្រទេសថៃ
- បានរៀបចំឯកសារបញ្ជូនគណៈប្រតិភូចំនួន១៣នាក់ ដើម្បីចូលរួមប្រជុំមន្ត្រីជាន់ខ្ពស់ ACCSM លើកទី១៨ "The Senior Officials Meeting of the 18thACCSM" នៅប្រទេសហ្វីលីពីន និង កិច្ចប្រជុំជំនួបស្តីពី "ACCSM Focal Point Meeting 2015" និង "Strategic Asian Civil Servants Visitors Program-SEACSVP" នៅប្រទេសថៃ
- បានរៀបចំឯកសារចាត់តាំងមន្ត្រីជាន់ខ្ពស់ចំនួន០៣នាក់ នៃក្រុមការងារវិមជ្ឈការ និង វិសហមជ្ឈការរបស់ក្រសួងមុខងារសាធារណៈដើម្បីទៅធ្វើទស្សនៈកិច្ចសិក្សានៅប្រទេសឥណ្ឌូនេស៊ី។

១.៧.អគ្គាធិការដ្ឋាន

- បានចុះពិនិត្យនិងស្រាវជ្រាវ (១)ករណីតែងតាំងលោក ឆាយ ដួងសារុធ ជាប្រធានស្តីទីនៃមន្ទីរបរិស្ថានខេត្តក្រចេះ (២)ករណីថ្ងៃកំណើតរបស់លោក សឿង សុងហៀក គ្រូបង្រៀននៅស្រុកពួកខេត្តសៀមរាប (៣)ជួបពិភាក្សាការងារជាមួយមន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីបំភ្លឺករណីលុបឈ្មោះលោក ពេជ្រ ណារ៉ុង ពីក្របខណ្ឌក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ (៤)ករណីលុបឈ្មោះប្រធាន ការិយាល័យចំនួន០២នាក់ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរីនិង (៥) ករណីតែតាំងប្រធានការិ យាល័យស្រុកប្រតិបត្តិពោធិ៍សែនជ័យ នៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ។

## ១.៨.សាលាភូមិន្ទរដ្ឋបាល

- បានចូលរួមក្នុងអង្គប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗចំនួន២៦លើក
- បានសម្របសម្រួលឱ្យសិស្សចុះកម្មសិក្សា៖ (ក)ផ្នែករដ្ឋបាលចំនួន២៨នាក់ ទៅក្រសួងចំនួន៦និងខេត្តចំនួន២ (ខ)ផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន២០នាក់ ទៅក្រសួង៥និងខេត្តចំនួន១ និង (គ)ផ្នែកការទូតចំនួន១៨នាក់ ទៅកាន់ក្រសួង១ និងអគ្គរាជទូតខ្មែរប្រចាំ៧ប្រទេស
- បាននឹងកំពុងរៀបចំការប្រឡងប្រជែងជ្រើសរើសសិស្សមន្ត្រីជំនាន់ទី៩ ដែលមានបេក្ខជនសរុបចំនួន៩៥៦នាក់ សម្រាប់ឆ្នាំសិក្សា២០១៦-២០១៨
- បានទទួលបេក្ខជនប្រឡងជាប់ជាស្ថាពរនៃសិស្សក្រមការជំនាន់ទី៦ ចំនួន៦០នាក់ ក្នុងនោះ០៥នាក់ បានបោះបង់ចោលការសិក្សា/ស្ត្រី០២នាក់
- កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់មានចំនួនសរុប១១៥នាក់/ស្ត្រី១១នាក់ ព្រះសង្ឃ៣អង្គ សិក្សាលើមុខវិជ្ជាចំនួន៣៣មុខវិជ្ជា(៨២៥ម៉ោង)
- កម្មសិក្សាការីមន្ត្រីមធ្យមមានចំនួនសរុប៨៣នាក់/ស្ត្រី១៨នាក់ ព្រះសង្ឃ៦អង្គ សិក្សាលើមុខវិជ្ជាចំនួន៣០មុខវិជ្ជា (៨០០ម៉ោង)
- កម្មសិក្សាការីមធ្យមថ្នាក់ក្រោមជាតិ ជំនាន់ទី១ នៃក្រសួងបរិស្ថានចំនួន២៣នាក់/ស្ត្រី០១នាក់ បានសិក្សាលើ១៦មុខវិជ្ជា (៣៥៦ម៉ោង) និង ជំនាន់ទី២ មានសិក្ខាកាមចំនួន២០នាក់/ស្ត្រី០៤នាក់ បានសិក្ខាលើ១៦មុខវិជ្ជា (៣៦២ម៉ោង)
- បានរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ស្តីពី "Public Management" ជូនដល់សិក្ខាកាមមកពី៣៤ក្រសួងស្ថាប័ន
- បានរៀបចំសិក្ខាសាលា សន្និសីទ និងបាឋកថាជូនសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៨ សិស្សមន្ត្រីក្រមការជំនាន់ទី៦ កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់និងមន្ត្រីមធ្យមព្រមទាំងសិក្ខាកាមថ្នាក់ក្រោមជាតិរបស់ក្រសួងបរិស្ថានចំនួន៣០ប្រធានបទ
- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ទីរទេសចរណ៍ និងមន្ត្រីរាជការរវាងក្រសួងមុខងារសាធារណៈ និង ក្រសួងទេសចរណ៍
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពី "ការវាយតម្លៃលើតម្រូវការសម្រាប់បណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល"
- បានរៀបចំពីធីប្រគល់វិញ្ញាបនបត្រជូនដល់កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ មន្ត្រីមធ្យម ឆ្នាំ២០១៤ សិក្ខាកាមមន្ត្រីមធ្យមនៃក្រសួងបរិស្ថាន និង បើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៥ ព្រមទាំងពិធីប្រកាសចូលកាន់មុខតំណែងជូនឯកឧត្តម យក់ ប៊ុនណា ជានាយកសាលាភូមិន្ទរដ្ឋបាល។

## ១.៩.ការងារសវនកម្មផ្ទៃក្នុង

- ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញសវនកម្មដូចជា៖(១)ច្បាប់ស្តីពីសវនកម្មនិងស្តង់ដារសេវាសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា (២)សវនកម្មលើកម្មវិធីបច្ចេកវិទ្យាព័ត៌មាន (៣)ការពង្រឹងការអនុវត្តសវនកម្មជាក់ស្តែង (៤)ការចុះសវនកម្មលើសមិទ្ធកម្ម និង (៥)ស្តង់ដារនៃការរៀបចំរបាយការណ៍បឋម និង របាយការណ៍សវនកម្មពេញលេញ
- បានចុះប្រមូលព័ត៌មាននិងធ្វើសវនកម្មនៅមន្ទីរមុខងារសាធារណៈចំនួន៧ខេត្ត បន្ទាយមានជ័យ បាត់ដំបង ព្រះវិហារ ក្រចេះ កំពង់ឆ្នាំង ពោធិ៍សាត់ និងព្រៃវែង ព្រមទាំងបានរៀបចំរបាយការណ៍សង្ខេបសវនកម្មជូនថ្នាក់ដឹកនាំក្រសួង និងរបាយការណ៍សវនកម្មពេញលេញជូនថ្នាក់ដឹកនាំក្រសួង និងអាជ្ញាធរសវនកម្មជាតិ
- បានចុះសិក្សាស្រាវជ្រាវ ហានិភ័យរបស់សវនដ្ឋាន និង រៀបចំផែនការយុទ្ធសាស្ត្រ៣ឆ្នាំរំកិល ២០១៦-២០១៨ ព្រមទាំងរៀបចំផែនការសវនកម្ម ផែនការអនុវត្តសវនកម្ម កម្មវិធីសវនកម្ម សម្រាប់ឆ្នាំ២០១៦ និងរៀបចំផែនការសកម្មភាពការងារឆ្នាំ២០១៦ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

១.១០.ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- បានចូលរួមប្រជុំគណៈកម្មាធិការដឹកនាំការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រុមការងារបច្ចេកទេសហិរញ្ញវត្ថុសាធារណៈ ព្រមទាំងសិក្ខាសាលាផ្សេងៗចំនួន២១លើក
- បាន (១)កសាងនូវផែនការសកម្មភាពរួមដំណាក់កាលទី៣(MAP3)២០១៦-២០១៨ (២)បានកែតម្រូវខ្លឹមសារនៃការវាយតម្លៃលើការចំណាយសាធារណៈ (PEFA) និង (៣)រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី១ទី២ និងទី៣ នៃការអនុវត្តន៍ផែនការសកម្មភាពដំណាក់កាលទី២ថ្មី (MAP2-NEW) ហើយបានផ្ញើទៅអគ្គលេខាធិការដ្ឋានដឹកនាំការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (GSC) រួចរាល់។

១.១១.ការងារកែទម្រង់រដ្ឋបាលសាធារណៈ

- បានរៀបចំ និង ដាក់កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ (NPAR) ២០១៥-២០១៨ ជូនអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីអនុម័តក្នុងសម័យប្រជុំកាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៥
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ NPAR នៅថ្នាក់ជាតិចំនួន០១លើក និង ថ្នាក់តំបន់ចំនួន០៦លើក ដោយមានការអញ្ជើញចូលរួមពីតំណាងគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ គណៈអភិបាលរាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្ត មន្ទីរជំនាញជុំវិញរាជធានី ខេត្ត អង្គភាពសេវាក្រៅ សាលាដំបូងរាជធានី ខេត្ត កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គ្រឹះស្ថានសាធារណៈ (រដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ អគ្គីសនីកម្ពុជា មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត សាកលវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យសុខាភិបាល សាកលវិទ្យាល័យភូមិន្ទកសិកម្ម និង វិទ្យាស្ថានជាតិបច្ចេកវិទ្យានៃកម្ពុជា) និងសង្គមស៊ីវិលដែលបំពេញការងារពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចរដ្ឋបាលសាធារណៈ
- បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងកម្រិតថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យ និង ពិភាក្សាលើសេចក្តីព្រាងឯកសារណែនាំ ស្តីពីប្រព័ន្ធតាមដាន ត្រួតពិនិត្យ និង វាយតម្លៃលើការអនុវត្ត NPAR២០១៥-២០១៨
- បានរៀបចំកិច្ចប្រជុំរវាងកំណែទម្រង់ទាំងបី(១)គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (២)គណៈកម្មាធិការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និង(៣)គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធត្រួតស៊ីគ្នាជុំវិញការអនុវត្តការងារកែទម្រង់ទាំងបី វិស័យការស្រង់ព័ត៌មានអំពីតម្រូវការបណ្តុះបណ្តាលកម្មវិធីបណ្តុះបណ្តាលនិងការងារពាក់ព័ន្ធ
- បានប្រជុំពិភាក្សាការងាររវាងដៃគូអភិវឌ្ឍន៍ JICA និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីពិភាក្សាលើទស្សនទានសម្រាប់ការគាំទ្ររបស់អាល្លឺម៉ង់ ចំពោះកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិនៅក្រសួងមហាផ្ទៃ
- បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ក.ការកែលម្អគុណភាពសេវាសាធារណៈ

- បានធ្វើទស្សនកិច្ចសិក្សាពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ នៅព្រះរាជាណាចក្រថៃ
- បានសម្របសម្រួលក្នុងការបង្កើតនិងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស (SOA) ចំនួន០៤កន្លែងបន្ថែមទៀត របស់ក្រសួងសុខាភិបាល
- បានរៀបចំនិងដាក់ឱ្យអនុវត្តសារាចរ ស្តីពីការកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ដោយមន្ត្រីដែលត្រូវចូលនិវត្តន៍នឹងទទួលបានប្រាក់ឧបត្ថម្ភដំបូងម្តងគត់មុនពេលចូលនិវត្តន៍ក្នុងគណនីរបស់ខ្លួនត្រឹមខែចុងក្រោយមុនកាលបរិច្ឆេទនៃការចូលនិវត្តន៍ និងប្រាក់សោធននិវត្តន៍ក្នុងខែបន្ទាប់
- បានចុះសិក្សាស្រាវជ្រាវនិង រៀបចំរបាយការណ៍បឋមជូនថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ក្រោយពីបានពិភាក្សាជាមួយក្រុមការងារនៃក្រសួងសាធារណៈការនិងដឹកជញ្ជូន ស្តីពីការផ្តល់សេវាសាធារណៈនៅមន្ទីរសាធារណៈការនិងដឹកជញ្ជូនរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងព្រះសីហនុ និង អគ្គនាយកដ្ឋានដឹកជញ្ជូន

ផ្លូវគោក ដោយផ្តោតលើការផ្តល់សេវាចំនួនបីប្រភេទ គឺ (១)ការត្រួតពិនិត្យលក្ខណៈបច្ចេកទេស (២) ការផ្តល់ ផ្លាកលេខយានយន្ត និង (៣)នីតិវិធីក្នុងការប្រឡងយកប័ណ្ណបើកបរយានយន្ត

- បានធ្វើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈ ចង្កោមទី១ ទី២ ទី៤-៧ ជាមួយក្រសួង ស្ថាប័ន ចំនួន២២ បញ្ចូលក្នុងសៀវភៅកម្រងព័ត៌មានសេវាសាធារណៈរួចរាល់ ព្រមទាំងបានកំណត់សេវាអាទិភាពចំនួន៨៧សេវា របស់ក្រសួង ស្ថាប័នចំនួន២០ ដើម្បីបង្កើនគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវា ព្រោះសេវាទាំងនោះ ពាក់ព័ន្ធផ្ទាល់នឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ
- បានរៀបចំអង្គប្រជុំផ្ទៃក្នុងចំនួន០៤លើក ដើម្បីពិនិត្យនិងពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការផ្តល់សេវាសាធារណៈ
- បាននិងកំពុងរៀបចំសម្របសម្រួលក្នុងការបង្កើតនិងដាក់ឱ្យអនុវត្តន៍ច្រកចេញចូលតែមួយរបស់ក្រសួង។

ខ.<u>ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស</u>

- បានបង្កើតក្រុមការងារសិក្សាលើចេនាសម្ព័ន្ធគំរូ អង្គភាពធនធានមនុស្ស និង ក្រុមការងារសិក្សាដាក់ឱ្យអនុវត្តន៍ ប្រព័ន្ធគុណផលការងារ ដើម្បីធ្វើការងារសម្របសម្រួលជាមួយអ្នកជំនាញការ GIZ
- បានកសាងសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងគុណផល (ផែនការការងារ ការពិពណ៌នា មុខតំណែង ការអភិវឌ្ឍសមត្ថភាព ផែនការបន្តវេន ផែនការអាជីព ការដំឡើងថ្នាក់-ឋានន្តរស័ក្តិ ជាដើម) និងបានដាក់ឆ្លងឯកសារនេះនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួងផងដែរ
- បានរៀបចំនិងដាក់ឱ្យអនុវត្តន៍សារាចរស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និង មុខតំណែងក្នុងរចនាសម្ព័ន្ធ គ្រប់គ្រងក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ (ថ្នាក់អគ្គនាយករងឡើងមិនឱ្យលើសពី០៥រូប ថ្នាក់អនុប្រធាននាយកដ្ឋានពី០៣នាក់ទៅ០៥នាក់ ថ្នាក់អនុប្រធានការិយាល័យពី០២ទៅ០៤នាក់ និងថ្នាក់ អនុប្រធានមន្ទីរជំនាញនៅរាជធានី ខេត្ត យ៉ាងច្រើន០៣នាក់)
- បានរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីកម្រិតជាន់ខ្ពស់ និង កម្រិតមធ្យម និង ការរៀបចំគម្រោង សម្រាប់ធ្វើការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល
- បានរៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីរាជការចំនួន១៩៦៥នាក់/ស្ត្រី៤៩២នាក់ នៃ ២៩ក្រសួងស្ថាប័ន និង១៤ រាជធានី ខេត្តក្រោមគម្រោងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់កម្មវិធីអភិវឌ្ឍន៍ជនបទអនុកម្មវិធីទី២ របស់ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ព្រមទាំងបានរៀបចំសិក្ខាសាលា ស្តីពីការវាយតម្លៃលើការអនុវត្តកម្មវិធី អភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការស៊ីវិល ២០១៤-២០១៥ ផងដែរ
- បានរៀបចំវគ្គបណ្តុះបណ្តាល (១)ស្តីពីវិស័យមុខងារសាធារណៈ ជូនថ្នាក់ប្រធាន-អនុប្រធានមន្ទីរ អនុប្រធាន នាយកដ្ឋាន ប្រធានការិយាល័យ នៃក្រសួងមុខងារសាធារណៈ ចំនួន១១២នាក់ដែលផ្តោតលើគោល នយោបាយមុខងារសាធារណៈនិងការគ្រប់គ្រងមុខងារសាធារណៈនិង (២)មន្ត្រីរាជការក្របខណ្ឌថ្មី ឆ្នាំ ២០១៤ ចំនួន៤៧នាក់
- បានរៀបចំកម្មវិធីចែករំលែកចំណេះដឹង និង បទពិសោធន៍សម្រាប់មន្ត្រីរាជការក្រសួងចំនួន០៣លើក ដែល មានសិក្ខាកាមចូលរួមចំនួន១៥០នាក់
- បានរៀបចំសិក្ខាសាលា ស្តីពីការរៀបចំមុខងាររចនាសម្ព័ន្ធនិងនីតិវិធីការងាររបស់អង្គភាពគ្រប់គ្រងធនធាន មនុស្សនៅក្នុងស្ថាប័ននៃវិស័យឯកជន អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល រដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ
- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលចំនួនពីរវគ្គដែលមានសិក្ខាកាមចូលរួម៥០នាក់ មកពីគ្រប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងវគ្គបណ្តុះបណ្តាលស្តីពីវិស័យមុខងារសាធារណៈ ជូនមន្ត្រី រាជការចំនួន១០០នាក់ ដែលមានសមាសភាពជាអាទិ៍ ប្រធាន-អនុប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត អនុប្រធាននាយកដ្ឋាន និងប្រធាន-អនុប្រធានការិយាល័យ

- បានធ្វើទស្សនៈកិច្ចសិក្សាទៅប្រទេសចិន និង ប្រទេសជប៉ុន ដើម្បីស្វែងយល់អំពី ការផ្តល់សេវាសាធារណៈ ការកែទម្រង់ប្រព័ន្ធបៀវត្ស ការគ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។

គ.<u>ការកែទម្រង់ប្រព័ន្ធបៀវត្ស (ក្រុមការងារកែទម្រង់ប្រព័ន្ធបៀវត្ស)</u>

- បានរៀបចំរបាយការណ៍ ស្តីពីការចំណាយលើបន្ទុកបុគ្គលិកនៅស្ថាប័នថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ និង វិធានការកែទម្រង់ប្រព័ន្ធបៀវត្សសម្រាប់រយៈពេល ២០១៦-២០១៨ ជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់
- បានបង្កើនបៀវត្សអប្បបរិមារបស់ (១)មន្ត្រីរាជការស៊ីវិល ដល់ ៥៥២៨០០រៀល (២)ប្រាក់បំណាច់មុខងារវិស័យអប់រំនិងសុខាភិបាលដល់ ៦៥២៨០០រៀល (៣)គិលានុបដ្ឋាកបឋមនិងឆ្មបបឋមដល់ ៦៥២៨០០រៀល (៤)ប្រាក់កម្រៃគ្រូបង្រៀនជាប់កិច្ចសន្យា ចំនួន ៤៤០០០០រៀល (៥)នគរបាលជាតិដល់ ៦២៨៣០០រៀល (៦)យោធិន ដល់ ៥៨២៤០០រៀល
- បានធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ថ្មី អនុលោមតាមខ្លឹមសារព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានរៀបចំប្រព័ន្ធបៀវត្សដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ព្រមទាំងធានាបាននូវសង្គតិភាពទាំងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ទាំងក្របខណ្ឌកងប្រដាប់អាវុធ ព្រមទាំងក្របខណ្ឌ និង នីតិបញ្ញត្តិ និង គ.ជ.ប
- បានកសាងលិខិតបទដ្ឋានគតិយុត្តចំនួន១៧ប្រភេទ ដូចខាងក្រោម៖
  +អនុក្រឹត្យស្តីពី (១)ការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្សជូនដល់យោធិន នៃកងយោធពលខេមរភូមិន្ទ (២)ការកែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិកម្ពុជា (៣)ការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ (៤)ការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល (៥)ប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងសុខាភិបាល (៦)ការបើកផ្តល់បៀវត្សមូលដ្ឋានប្រាក់បន្ទាប់បន្សំនៃបៀវត្ស និង របបឧបត្ថម្ភផ្សេងៗ ជូនមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ (៧)ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ (៨)ការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន (៩) ការកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែ ចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (១០)ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនិង (១១)ការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា
  +សារាចរស្តីពី (១)វិធានការសម្រាប់គ្រប់គ្រងមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ក្នុងឆ្នាំ២០១៥ និង (២)ការបើកផ្តល់បៀវត្សសម្រាប់ខែមេសា ឆ្នាំ២០១៥ និងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមែ សប្តស័ក ព.ស.២៥៥៩ និង (៣) ការកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍
  +សេចក្តីណែនាំស្តីពី (១)ការពង្រឹងការប្រើប្រាស់និងការបើកផ្តល់ប្រាក់កម្រៃដល់មន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត និង (២)ការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ
  +សេចក្តីជូនដំណឹងស្តីពីការបោះពុម្ពតារាងទូទាត់បៀវត្សប្រចាំខែមេសា និង ខែតុលា ឆ្នាំ២០១៥ ជូនមន្ត្រីរាជការស៊ីវិល
- បានរៀបចំក្រុមការងារចុះត្រួតពិនិត្យប្រមូលព័ត៌មាន និង ទិន្នន័យលើការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការជាគ្រូបង្រៀននិងមន្ត្រីរដ្ឋបាល គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនជាប់កិច្ចសន្យានៅសាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ទូទាំង២៥រាជធានី ខេត្ត

+សេចក្តីជូនដំណឹងស្តីពីការបោះពុម្ពតារាងទូទាត់បៀវត្សប្រចាំខែមេសា និង ខែតុលា ឆ្នាំ២០១៥ ជូនមន្ត្រីរាជការស៊ីវិល

- បានរៀបចំក្រុមការងារចុះត្រួតពិនិត្យប្រមូលព័ត៌មាន និង ទិន្នន័យលើការប្រើប្រាស់ក្របខណ្ឌមន្ត្រីរាជការជាគ្រូបង្រៀននិងមន្ត្រីរដ្ឋបាល គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនជាប់កិច្ចសន្យានៅសាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ទូទាំង២៥រាជធានី ខេត្ត
- បានរៀបចំកិច្ចប្រជុំជាមួយក្រសួងអប់រំយុវជននិងកីឡាអំពីករណីអតីតភាពការងាររបស់គ្រូបង្រៀនក្រោយធ្វើសមាហរណកម្មតាមព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានរៀបចំកិច្ចប្រជុំពិភាក្សាស្តីពីការដំឡើងបៀវត្សសម្រាប់ (១)សមាជិក គជប និង មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គជប (២)អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋសភា និងព្រឹទ្ធសភា (៣)ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម និង (៤)អាជ្ញាធរសវនកម្មជាតិ
- បាននិងកំពុងរៀបចំវិធានការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ដើម្បីមានលទ្ធភាពដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការចំនួនមួយលានរៀលក្នុងមួយខែនៅឆ្នាំ២០១៨
- បាននិងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត
- ត្រៀមដាក់បញ្ចូលបញ្ជីឈ្មោះមន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងអប់រំ យុវជន និងកីឡា ចូលក្នុងតារាងទូទាត់បៀវត្សឆ្នាំសិក្សាថ្មី២០១៥-២០១៦។

**១.១២.<u>ក្រុមការងារវិមជ្ឈការនិងវិសហមជ្ឈការ</u>**

- បានចុះពិគ្រោះយោបល់ដើម្បីរៀបចំប្រព័ន្ធគ្រប់គ្រងគុណផលនៅថ្នាក់ក្រោមជាតិតាមបណ្តាខេត្តគោលដៅចំនួន ០៨ខេត្ត
- បានផ្សព្វផ្សាយគោលនយោបាយស្តីពីការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ០៦លើក
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងជំរុញការអនុវត្តអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ ០៨ លើក
- បានរៀចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីតាក់តែងសេចក្តីព្រាងនិងកែសម្រួលលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១៦លើក
- បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់របស់អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៃគ.ជ.អ.ប ចំនួន ០៣លើក
- បានកសាងសេចក្តីព្រាងចុងក្រោយ នៃលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិជូន គ.ជ.អ.ប
- បានទៅធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីការអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការនៅប្រទេសឥណ្ឌូនេស៊ី

**១.១៣.<u>ក្រុមការងារយេនឌ័រ</u>**

- បានរៀបចំបោះពុម្ព និង ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨
- បានរៀបចំកិច្ចប្រជុំពិភាក្សាវគ្គបណ្តុះបណ្តាលចំនួន០៩លើក ក្រោមប្រធានបទស្តីពី (១)ការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ (២)ពង្រឹងសមត្ថភាពអ្នកសម្របសម្រួល (៣)ផ្សព្វផ្សាយផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈដំណាក់កាលទី៣ ឆ្នាំ២០១៤-២០១៨ (៤)ស្តីពីសេចក្តីព្រាង

- បានធ្វើបទបង្ហាញស្តីពីទស្សនវិស័យនៃការបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ និង គោលការណ៍ណែនាំសំខាន់ៗក្នុងវគ្គបណ្តុះបណ្តាល ស្តីពីទស្សនៈជាលក្ខណៈគ្រឹះនិងការបញ្ជ្រាបយេនឌ័រដល់ថ្នាក់ដឹកនាំក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

## ២.អង្គភាពថ្នាក់ក្រោមជាតិ

### ២.១.ការប្រើប្រាស់ក្របខណ្ឌនិងឥណទានបៀវត្ស

| ល.រ | រាជធានី-ខេត្ត | ចំនួនមន្ត្រី/បុគ្គលិក មន្ទីរ.ម.ស | | | | ចំនួនមន្ត្រីទូទាំង រាជធានី-ខេត្ត | | ប្រពន្ធ | កូន | ឥណទានបៀវត្ស | ចំនួនមន្ត្រីជាប់កិច្ចសន្យា | ចំនួនបុគ្គលិកអណ្តែត | ផ្សេងៗ[1] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | កិច្ចសន្យា | អណ្តែត | សរុប | ស្រី | | | | | | |
| ១ | ប.មានជ័យ | ១៣ | ៥ | ៣ | ២ | ៧៩៥៤ | ៣៣២១ | ២៥៩៣ | ៦០៤០ | ៧០២៨៣៥២៩២២៨ | ៣៩៣ | ២០៩ | ៩២៧៧ |
| ២ | បាត់ដំបង | ១៥ | ៣ | ៣ | ២ | ១២០៦២ | ៥៧៤៦ | ៣៣៤២ | ១០៩៧៤ | ៧៥២៣១៤៤៦៦៩០ | ៤៥៦ | ៤៩៤ | ២១៤៥ |
| ៣ | កំពង់ចាម | ១៥ | ៤ | ៣ | ២ | ៩៩០៧ | ៤៤៩៥ | ៣១០៣ | ១១៤៤២ | ៩២០៤០០១៥៣៥៣ | ៤២៧ | ៣៤៨ | ៣០០ |
| ៤ | កំពង់ឆ្នាំង | ១៤ | ៦ | ៣ | ២ | ៥៩៤៩ | ២៤៤១ | ២០១៨ | ៥៨០៤ | ៥៣៧៩៩៤៦១៧៤៩ | ៤៦៤ | ១៦៥ | ១១ |
| ៥ | កំពង់ស្ពឺ | ១៤ | ៥ | ៣ | ២ | ៧២៩៣ | ២៧០៦ | ២៩៩០ | ៧៨១៧ | ៦៧១៩៩០២១០៤៧ | ៤៧៨ | ២០០ | ១២៩២ |
| ៦ | កំពង់ធំ | ១៣ | ៣ | ៣ | ២ | ៧០៤៣ | ៣១១៦ | ២២១៥ | ៧៤៦៤ | ៦៦២១៩៦៣២០៦០ | ៣៥២ | ៣១១ | |
| ៧ | កំពត | ១០ | ៣ | ៣ | ២ | ៨០០៥ | ៣១៦៨ | ២៧០៦ | ៧៧៦៩ | ៧០៥៦៥៥៨៥៤៥៤ | ២៤៤ | ២២៨ | ២៦៤០ |
| ៨ | កណ្តាល | ១៣ | ២ | ៣ | ២ | ១១៥៨២ | ៥៣១៦ | ៣៨១៦ | ១១៨០០ | ១០៨៨៣៦៥៦៧៦៤៩ | ៥៦៧ | ២៧០ | ១១៣៧ |
| ៩ | កោះកុង | ៧ | ៣ | ៣ | ២ | ២២១៣ | ៧៣៧ | ៦៤៨ | ១៤៨០ | ១៩៩៥០២៩១៦៩០ | ១៣១ | ១១០ | ៦៣៦ |
| ១០ | ក្រចេះ | ៧ | ១ | | | ៤៤៤១ | ២១៨១ | ១០០៧ | ៣៦៥៩ | ៣២៧៩៨៦៦១២០ | ១៦៦ | ២១៦ | ៦២ |
| ១១ | មណ្ឌលគិរី | ១២ | ៨ | ៣ | ២ | ១៦៤៨ | ៦១៥ | ៣៨៧ | ៨០៩ | ១០៤០២២៤៦៣៧៦ | ១០៣ | ១៦៦ | ១៣០៣ |
| ១២ | រាជធានីភ្នំពេញ | ១៣ | ៥ | ៣ | ២ | ១៤៣៤៩ | ៧៣៦២ | ១៩៤០ | ៤៦៧ | ១៣២៧៤៤៦៣៥៨៦១ | ៥៧២ | ២៣៨៨ | ២៣៩៨ |
| ១៣ | ព្រះវិហារ | ១០ | ៤ | ៣ | ២ | ៣៣៩៥ | ១២៥៨ | ៤៥ | ១៩២ | ២៥៧៦០៩៣១២៤០ | ១២៣ | ២៦១ | ១២៣៦ |
| ១៤ | ព្រៃវែង | ១២ | ៤ | ២ | ៣ | ១០១៤០ | ៣៧៧៥ | ៤១១៣ | ១២២២៧ | ៩៥៦៩៤៣៦២៣៨៨ | ២៣៧ | ២៥៦ | ៥៥៥៦ |
| ១៥ | ពោធិ៍សាត់ | ១២ | ៦ | ៣ | ២ | ៥៤៤៣ | ២១៦៣ | ១៨៣០ | ៥០៥៤ | ៥០២៣៨៤៩០៤៨៨ | ៣១១ | ១៩៦ | ១៣៦៩ |
| ១៦ | រតនគិរី | ១៦ | ៣ | ៣ | ២ | ២៤៤៧ | ៨០១ | ៧២៥ | ១៤៩៧ | ២២៤១៥៨៩៤០២៧ | ៤២១ | ១២០ | ៧១០ |
| ១៧ | សៀមរាប | ១៤ | ៦ | ៣ | ២ | ៩២៣០ | ៤៦១៦ | ២១៣២ | ៦៦១២ | ៤៨៩៦៩៩៣៨៨០០ | ១០៨៧ | ៣៨០ | ៤១៧៣ |
| ១៨ | ព្រះសីហនុ | ១៣ | ៦ | ៣ | ២ | ៣១៨២ | ១២០៤ | ១០២៨ | ២៩០៤ | ២៧៦៩៥៧១៣៤៦៧ | ១៤១ | ៦៩ | ៦០៤ |
| ១៩ | ស្ទឹងត្រែង | ១១ | ៦ | ៤ | ២ | ២៤៨០ | ១០៥៦ | ៥៤៣ | ១៤៨៧ | ២២៣១៤២០៦១៥៥ | ១៤៨ | ១៨៨ | |
| ២០ | ស្វាយរៀង | ១៤ | ២ | ៣ | ២ | ៦៤៥៦ | ២០២៥ | ២៨២៤ | ៦៦៣៤ | ៥៩៣២២៣០៧៤៨០ | ២១២ | ២៧០ | ១២១១ |
| ២១ | ត្បូងឃ្មុំ | ៨ | ៣ | ៣ | ២ | ៥៤៦៤ | ២៣៤៥ | ១៦៥៨ | ៥៣០៧ | ៥៣៣៦៧៧០៧៨៤៨ | ៣៦៧ | ២៥៣ | |
| ២២ | តាកែវ | ១១ | ១ | ៣ | ២ | ១០៧០២ | ៩៤៧ | ៤៧១២ | ១៥៤៦២ | ៩៨៦៨២៧៩៤៨៨៤ | ២៤៨ | ២០៩ | ៧៤ |
| ២៣ | កែប | ១១ | ១ | ៣ | ២ | ១១៨៩ | ៤៤៣ | ២៩០ | ៧៧៧ | ១០៣៧៥៣០០៣៣០ | ១១៤ | ១០៦ | |
| ២៤ | ប៉ៃលិន | ១៤ | ៥ | ៣ | ២ | ១៥១០ | | ៤៥០ | ៩៥២ | ១៤០៩០១៣៧៩៨២ | ១៦៣ | ១៨០ | |
| ២៥ | ឧត្តមានជ័យ | ១០ | ៤ | ៣ | ២ | ២៧១៨ | ៨៦០ | ៨៧៧ | ១៩៩០ | ១៩៧៥១៤៦២២០០ | ១៥៨ | ២៤៧ | ៣៩២ |
| | សរុប | ៣០២ | ៩៩ | ៧២ | ៤៩ | ១៦៣៩៦៥ | ៦២៦៩៧ | ៤៦១៩២ | ១៣៦៦២០ | ១៣១៩២៣១៥៤៦៥៦៦ | ៧៦២៧ | ៥៤៥២ | ៣៦៤៤១ |

### ២.២.បញ្ហាប្រឈមក្នុងការអនុវត្តដែនសមត្ថកិច្ចរបស់មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត

- បន្ទប់ធ្វើការតូចចង្អៀតនិងខ្វះមធ្យោបាយបំពេញការងារ (សម្ភារៈការិយាល័យនិងរថយន្ត)
- មិនទាន់មានមន្ត្រីគ្រប់គ្រាន់ ដើម្បីបំពេញរចនាសម្ព័ន្ធមន្ទីរ តាមប្រកាសលេខ ១៩៧៩ មស.គន ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរមុខងារសាធារណៈរាជធានីខេត្ត បន្ទាយមានជ័យ កំពង់ស្ពឺ កំពត ក្រចេះ ព្រះវិហារ ស្ទឹងត្រែង ត្បូងឃ្មុំ កែប និង ឧត្តរមានជ័យ
- សមត្ថភាពមន្ត្រីនៅមានកម្រិតនិងខ្វះឯកសារពាក់ព័ន្ធនឹងគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- អង្គភាពមួយចំនួនយឺតយ៉ាវក្នុងការបញ្ជូនសំណុំឯកសារប្រាក់បៀវត្ស ដើម្បីស្នើសុំទិដ្ឋាការពីមន្ទីរ មស។

[1]ការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិល

III.**សេចក្តីសន្និដ្ឋាន**

ក្នុងរយៈពេល១ឆ្នាំកន្លង មកក្រសួងមុខងារសាធារណៈ បានដឹកនាំនិងសម្របសម្រួលការងារគ្រប់គ្រងវិស័យមុខងារសាធារណៈ និង កែទម្រង់រដ្ឋបាលសាធារណៈ ជាពិសេសការសហការជាមួយអគ្គលេខាធិការដ្ឋានកែទម្រង់ពីរទៀតសម្រេចបាននូវសមិទ្ធផលជាច្រើនគួរជាទីមោទនៈ។ ការប្តេជ្ញាចិត្ត ភាពជាម្ចាស់ និងភាពដឹកនាំរបស់ក្រសួងមុខងារសាធារណៈ ក្នុងការបន្តកិច្ចការដែលបាននិងកំពុងដំណើរការគួបផ្សំនឹងវិធានការណ៍ដោះស្រាយ ការលើកទឹកចិត្ត និងមានការគាំទ្រពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសាធារណៈជន នឹងផ្តល់ថាមពលខ្លាំងឡើងដល់ការងារដឹកនាំ និង គ្រប់គ្រងវិស័យមុខងារសាធារណៈ ព្រមទាំងការងារកែទម្រង់រដ្ឋបាលសាធារណៈ។ ក្រសួងនឹងបន្តអនុវត្តមុខងារនិងបេសកកម្មរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ឈរលើគោលការណ៍ដូចមានចែងក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ កម្មវិធីជាតិអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល ដើម្បីសម្រេចឱ្យបាននូវសមិទ្ធផលថ្មីៗ បន្ថែមទៀតជាប្រយោជន៍ដល់សង្គមជាតិ។

IV.**ទិសដៅការងារ**

- បន្តរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ ច្បាប់ (១)ច្បាប់ស្តីពីការបង្កើតទីស្តីការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (២)ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ (៣)ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (៤)អនុក្រឹត្យស្តីពីការគ្រប់គ្រងវត្តមានរបស់មន្ត្រីរាជកាស៊ីវិលនិងមន្ត្រីជាប់កិច្ចសន្យា
- បន្តទទួលពាក្យបណ្តឹងនិងអង្កេតស្រាវជ្រាវពាក់ព័ន្ធនឹងវិវាទមុខងារសាធារណៈនិងបន្តចុះធ្វើអធិការកិច្ចអំពីភាពមិនប្រក្រតីក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិទាំងថ្នាក់ក្រោមជាតិ
- បន្តអនុវត្តផែនការអនុវត្តសកម្មភាពដំណាក់កាលទី៣ទី២ (២០១៥-២០១៧) នៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តអនុវត្តផែនការយុទ្ធសាស្រ្តបញ្ញាបយេនឌ័រ ក្នុងវិស័យមុខងារសាធារណៈដំណាក់កាលទី៣ ឆ្នាំ២០១៦-២០១៨
- បន្តអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៥-២០១៨
- បន្តពិនិត្យសំណើរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាលនិងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលការប្រើប្រាស់ក្របខណ្ឌមន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត ព្រមទាំងធ្វើសមទិន្នព័ត៌មានទៅក្នុងសលាកប័ត្រព័ត៌មានរបស់មន្ត្រីរាជការស៊ីវិល
- បន្តរៀបចំថវិកាតាមកម្មវិធីអង្គភាពថវិកាដើម្បីអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បន្តធ្វើវិភាគមុខងារនិងវំហូរការងារសម្រាប់សេវាសាធារណៈ ដែលមានផលប៉ះពាល់ដោយផ្ទាល់លើជីវភាពប្រចាំថ្ងៃរបស់មន្ត្រីរាជការនិងប្រជាពលរដ្ឋដូចជា ការបើកផ្តល់ប្រាក់បេសកកម្មដល់មន្ត្រីរាជការ ការបើកផ្តល់ប្រាក់ឧបត្ថម្ភនិងប្រាក់សោធននិវត្តន៍ដល់និវត្តជន ការចុះបញ្ជីយានយន្ត ការចុះបញ្ជីដីធ្លី ការចុះបញ្ជីអាជីវកម្ម ការផ្តល់អាជ្ញាបណ្ណសាង់សង់ ការផ្តល់សំបុត្រអាគ្រានុកូលដ្ឋាន អត្តសញ្ញាណបណ្ណ និងលិខិតឆ្លងដែនជាដើម។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ពេជ្រ ប៊ុនធិន**